# ព្រះរាជាណាចក្រកម្ពុជា

រាជរដ្ឋាភិបាលកម្ពុជា ជាតិ សាសនា ព្រះមហាក្សត្រ

លេខៈ ៧២ អនក្រ.បក

## អនុក្រឹត្យ

## ស្តីពី

## ការរៀបចំ និងការប្រព្រឹត្តិទៅរបស់

## អគ្គលេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិប្រជាជន និងការអភិវឌ្ឍ

---

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែកក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រម លេខ នស/រកម/០១៩៦/០៩ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពី ការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨០៤/២៣៧ ចុះថ្ងៃទី ៣១ ខែ សីហា ឆ្នាំ ២០០៤ ស្តីពីការបង្កើតគណៈកម្មាធិការជាតិប្រជាជន និងការអភិវឌ្ឍ
- តាមសំណើរបស់ រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី

## សម្រេច

## ជំពូកទី១

## បទប្បញ្ញត្តិទូទៅ

**មាត្រា ១.-**

អនុក្រឹត្យនេះ មានគោលដៅកំណត់បេសកកម្ម មុខងារ ភារកិច្ច និងរចនាសម្ព័ន្ធ របស់អគ្គលេខាធិការដ្ឋាន **គ.ជ.ប.អ**។

## ជំពូកទី២

## បេសកកម្ម និងភារកិច្ច

**មាត្រា ២.-**

គណៈកម្មាធិការជាតិប្រជាជន និងការអភិវឌ្ឍ សរសេរកាត់អក្សរខ្មែរ **គ.ជ.ប.អ** មានអគ្គលេខាធិការដ្ឋានមួយជាជំនួយការ។ អគ្គលេខាធិការដ្ឋាននេះដឹកនាំ និងគ្រប់គ្រងដោយអគ្គលេខាធិការមួយរូប និងអមដោយអគ្គលេខាធិការរង មួយចំនួនជាជំនួយការ ព្រមទាំងមានផ្នែកជំនាញផ្សេងៗទៀតតាមតម្រូវការចាំបាច់។

**មាត្រា ៣.-**

អគ្គលេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិប្រជាជន និងការអភិវឌ្ឍ សរសេរកាត់អក្សរខ្មែរ **អ.គ.ជ.ប.អ** មានបេសកកម្ម និងភារកិច្ចជាជំនួយការរបស់ **គ.ជ.ប.អ** លើការងារមួយចំនួនដូចតទៅ÷

- ស្រាវជ្រាវ និងផ្សព្វផ្សាយពត៌មានស្តីពីសេចក្តីត្រូវការ និងបញ្ហាទាំងឡាយដែលពាក់ព័ន្ធនឹងប្រជាជនជូនរាជរដ្ឋាភិបាល ស្ថាប័ន និងអង្គភាពពាក់ព័ន្ធនានា
- សម្របសម្រួល និងធ្វើសហប្រតិបត្តិការជាមួយនឹងក្រសួង និងស្ថាប័នពាក់ព័ន្ធ តំណាងភ្នាក់ងារ អង្គការសហប្រជាជាតិ ជាពិសេសមូលនិធិសហប្រជាជាតិសំរាប់ប្រជាជន (UNFPA) អង្គការក្រៅរដ្ឋាភិបាលជាតិ និងអន្តរជាតិ និងសង្គមស៊ីវិល ផ្នែកឯកជន និងតំណាងវិទ្យាស្ថានស្រាវជ្រាវដែលពាក់ព័ន្ធនឹងបញ្ហាប្រជាជន និងការអភិវឌ្ឍ ដើម្បីធានានូវភាពរលូន និងភាពជាដៃគូក្នុងការអនុវត្តកម្មវិធីនយោបាយ និងយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាល
- សម្របសម្រួលជាមួយគណៈកម្មការនៃរដ្ឋសភា និងព្រឹទ្ធសភាក្នុងក្របខ័ណ្ឌជាតិ ដែលពាក់ព័ន្ធនឹងបញ្ហាប្រជាជន និងចូលរួមដឹកនាំសិក្ខាសាលា វគ្គបណ្តុះបណ្តាល សន្និសីទជាតិ និងអន្តរជាតិ ដើម្បីជាជំនួយក្នុងការសំរេចគោលដៅ កម្មវិធីគោលនយោបាយ និងយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាល
- ចងក្រង និងផ្សព្វផ្សាយឯកសារគោលនយោបាយ ផែនការ កម្មវិធី និងសេចក្តីប្រកាសដែលពាក់ព័ន្ធនឹងបញ្ហាប្រជាជន និងការអភិវឌ្ឍ

- ត្រួតពិនិត្យ និងកែសម្រួលគោលនយោបាយប្រជាជន និងយុទ្ធសាស្ត្រជាតិប្រជាជនអោយកាន់តែល្អប្រសើរ តាមការវិវត្តន៍ នៃសភាពការណ៍ក្នុងតំបន់ និងពិភពលោក
- សហការជាមួយក្រសួងអប់រំ យុវជន និងកីឡា ក្រសួងសុខាភិបាល និងក្រសួងពត៌មាន ក្នុងការផ្សព្វផ្សាយ និងបញ្ចូលបញ្ហាប្រជាជនទៅក្នុងកម្មវិធីសិក្សានៅតាមគ្រឹះស្ថាននានា
- ធ្វើរបាយការណ៍ ប្រចាំត្រីមាស ឆមាស ប្រាំបួនខែ និងប្រចាំឆ្នាំ អំពីសកម្មភាពការងារតាមកាលកំណត់អោយបានទៀងទាត់ជូនប្រមុខរាជរដ្ឋាភិបាល។

មាត្រា ៤.-

អ.គ.ជ.ប.អ. ត្រូវធ្វើការប្រជុំការងារយ៉ាងតិចមួយដងក្នុងមួយខែ តាមការអញ្ជើញ និងការណែនាំរបស់អគ្គលេខាធិការ ។

មាត្រា ៥.-

អ.គ.ជ.ប.អ មានសិទ្ធិប្រើត្រារបស់ទីស្តីការគណៈរដ្ឋមន្ត្រី ដើម្បីបំពេញការងាររបស់ខ្លួន។

មាត្រា ៦.-

- អ.គ.ជ.ប.អ មានសិទ្ធិប្រើប្រាស់មន្ត្រីមុខងារសាធារណៈ និងលើកសំណើជូនប្រធាន គ.ជ.ប.អ ដើម្បីជ្រើសរើសបុគ្គលិកជាប់កិច្ចសន្យាតាមការចាំបាច់។
- មន្ត្រីរបស់ អ.គ.ជ.ប.អ អាចទទួលនូវប្រាក់ឧបត្ថម្ភផ្សេងៗ ដែលបានផ្តល់មកពីក្នុង និងក្រៅប្រទេស ឬ អង្គការអន្តរជាតិនានាដែលផ្តល់ជំនួយ។

មាត្រា ៧.-

អ.គ.ជ.ប.អ លើកសំណើជូនប្រធាន គ.ជ.ប.អ លើការតែងតាំង តម្លើងឋានៈ ផ្ទេរភារកិច្ច ឬ ដកចេញពីតំណែងនូវមន្ត្រីបុគ្គលិករបស់ អ.គ.ជ.ប.អ ។

## ជំពូកទី៣
## រចនាសម្ព័ន្ធ

មាត្រា ៨.-

អ.គ.ជ.ប.អ មានរចនាសម្ព័ន្ធដូចខាងក្រោមៈ

ក. ផ្នែករដ្ឋបាលទូទៅ និងគណនេយ្យ

ខ. ផ្នែកទំនាក់ទំនង និងផ្សព្វផ្សាយ

គ. ផ្នែកវិភាគគោលនយោបាយប្រជាជន

ឃ. ផ្នែកបណ្តុះបណ្តាល និងការអភិវឌ្ឍ

អង្គការលេខរបស់ អ.គ.ជ.ប.អ ជាឧបសម្ព័ន្ធនៃអនុក្រឹត្យនេះ។

មាត្រា ៩.-

-ផ្នែកជំនាញនីមួយៗ ត្រូវបែងចែកជាក្រុមជំនាញ។ ការបែងចែកភារកិច្ចទទួលខុសត្រូវរបស់ក្រុមជំនាញនីមួយៗ ត្រូវកំណត់ដោយប្រកាស តាមសំណើរបស់អគ្គលេខាធិការ។

មាត្រា ១០.-

ផ្នែកជំនាញដែលចំណុះ **អ.គ.ជ.ប.អ** ស្ថិតនៅក្រោមការដឹកនាំ និងការទទួលខុសត្រូវរបស់ប្រធានមួយរូប និងមានអនុប្រធានមួយចំនួន ជាជំនួយការតាមតម្រូវការចាំបាច់។

- ប្រធានផ្នែកជំនាញមានឋានៈស្មើប្រធាននាយកដ្ឋាន។
- អនុប្រធានផ្នែកជំនាញមានឋានៈស្មើអនុប្រធាននាយកដ្ឋាន។
- ប្រធានក្រុមជំនាញមានឋានៈស្មើប្រធានការិយាល័យ។

មាត្រា ១១.-

អគ្គលេខាធិការមានភារកិច្ចលើកសំណើជូនប្រធាន **គ.ជ.ប.អ** ដើម្បីពិនិត្យ និងសម្រេចលើការផ្លាស់ប្តូរ ឬ បង្កើតផ្នែកជំនាញ ក្រុមជំនាញ ផ្សេងៗទៀតតាមតម្រូវការចាំបាច់ ។

## ជំពូកទី៤
## តួនាទី និងភារកិច្ចរបស់ផ្នែក

មាត្រា ១២.-

**ផ្នែករដ្ឋបាលទូទៅ និងគណនេយ្យ មានតួនាទី និងភារកិច្ចៈ**

- ជាលេខាធិការដ្ឋានរបស់អគ្គលេខាធិការដ្ឋាន និងជាសេនាធិការផ្ទាល់ឱ្យអគ្គលេខាធិការ ដើម្បីសម្របសម្រួលផ្នែករដ្ឋបាល លើរាល់សកម្មភាពរបស់ផ្នែក និងក្រុមកិច្ចការទាំងអស់ក្រោមឱវាទរបស់អគ្គលេខាធិការដ្ឋាន
- គ្រប់គ្រងកិច្ចការរដ្ឋបាល និងគ្រប់គ្រងមន្ត្រី បុគ្គលិករបស់អគ្គលេខាធិការដ្ឋាន
- ប្រមូល ចងក្រងពត៌មាន និងឯកសារនានាពាក់ព័ន្ធដល់គោលនយោបាយជាតិប្រជាជន និងការអភិវឌ្ឍ
- រៀបចំគំរោងថវិកា សំភារៈបរិក្ខា និងមធ្យោបាយការងារផ្សេងៗ
- រៀបចំប្រព័ន្ធគ្រប់គ្រងព័ត៌មានវិទ្យា និងបង្កើតកម្មវិធីនានា
- គ្រប់គ្រងអចលនវត្ថុ ចលនវត្ថុ និងរាល់ការចំណាយផ្សេងៗ
- បូកសរុប និងធ្វើរបាយការណ៍ស្តីពីសកម្មភាពការងារប្រចាំខែ ត្រីមាស ឆមាស ប្រាំបួនខែ និងប្រចាំឆ្នាំ របស់ **គ.ជ.ប.អ**
- បំពេញភារកិច្ចផ្សេងៗទៀតតាមការប្រគល់ជូនរបស់អគ្គលេខាធិការនៃ **គ.ជ.ប.អ**។

មាត្រា ១៣.-

**ផ្នែកទំនាក់ទំនង និងផ្សព្វផ្សាយមានតួនាទី និងភារកិច្ច :**

- ស្រាវជ្រាវ ផ្សព្វផ្សាយ និងជូនពត៌មាន ស្តីពីសេចក្តីត្រូវការ និងបញ្ហាទាំងឡាយ ដែលពាក់ព័ន្ធនឹងប្រជាជន ជូនរាជរដ្ឋាភិបាល ស្ថាប័ន និងអង្គភាពពាក់ព័ន្ធនានា
- សិក្សាស្រាវជ្រាវ និងផ្តួចផ្តើមគំនិតថ្មីៗ ដែលទាក់ទងនឹងបញ្ហាប្រជាជន ដើម្បីធ្វើការតស៊ូមតិ
- ចូលរួមរៀបចំ និងដឹកនាំសិក្ខាសាលា សន្និសីទជាតិ និងអន្តរជាតិ ដើម្បីពន្យល់ និងផ្តល់ពត៌មានអំពីគំនិត នៃគោលនយោបាយជាតិប្រជាជន ដល់អ្នកធ្វើគោលនយោបាយ និង អ្នកធ្វើផែនការ អ្នកធ្វើការសម្រេចចិត្ត សភា និងព្រឹទ្ធសភា ដើម្បីអោយគាំទ្រ និងអនុវត្តគោលនយោបាយឱ្យមានប្រសិទ្ធភាព
- រៀបចំអត្ថបទ និងបោះពុម្ពព្រឹត្តិប័ត្រ សម្រាប់ផ្សព្វផ្សាយដល់ស្ថាប័នពាក់ព័ន្ធនានា
- បំពេញភារកិច្ចផ្សេងៗទៀតតាមការប្រគល់ជូនរបស់អគ្គលេខាធិការនៃ **គ.ជ.ប.អ**។

មាត្រា ១៤.-

**ផ្នែកវិភាគគោលនយោបាយប្រជាជន និងមានតួនាទី និងភារកិច្ច :**

- សិក្សាស្រាវជ្រាវ វិភាគ និងកែលំអគោលនយោបាយជាតិប្រជាជន
- សហការជាមួយគណៈកម្មការនៃសភា និងព្រឹទ្ធសភា ក្នុងក្របខ័ណ្ឌជាតិ ដែលពាក់ព័ន្ធនឹងបញ្ហាប្រជាជន និងការអភិវឌ្ឍ ដើម្បីជាជំនួយក្នុងការអនុវត្តអោយសំរេចនូវកម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាល
- សហប្រតិបត្តិការជាមួយក្រសួងពាក់ព័ន្ធ អង្គការជាតិ និងអន្តរជាតិ ប្រទេសផ្តល់ជំនួយ សង្គមស៊ីវិល ផ្នែកឯកជនដែលពាក់ព័ន្ធនឹងបញ្ហាប្រជាជន និងការអភិវឌ្ឍ ដើម្បីធានានូវភាពរលូន និងភាពជាដៃគូក្នុងការអនុវត្តគោលនយោបាយរបស់រាជរដ្ឋាភិបាល
- បំពេញភារកិច្ចផ្សេងៗទៀតតាមការប្រគល់ជូនរបស់អគ្គលេខាធិការនៃ **គ.ជ.ប.អ**។

មាត្រា ១៥.-

**ផ្នែកបណ្តុះបណ្តាល និងការអភិវឌ្ឍមានភារកិច្ច :**

- រៀបចំ និងអភិវឌ្ឍកម្មវិធីបណ្តុះបណ្តាលផ្សេងៗ
- ចូលរួមរៀបចំ និងអភិវឌ្ឍកម្មវិធីបណ្តុះបណ្តាលដល់មន្ត្រីរាជការតាមក្រសួង មន្ទីរ តាមតំបន់ និងខេត្ត ក្រុង ដើម្បីបង្កើនចំណេះដឹង និងស្វែងយល់អំពីទំនាក់ទំនងរវាងបញ្ហាប្រជាជន និងការអភិវឌ្ឍ
- សិក្សាស្រាវជ្រាវ និងរៀបចំកម្មវិធីដើម្បីបង្កើតយន្តការផ្លាស់ប្តូរបទពិសោធន៍ និងទស្សនៈជាវិជ្ជមាន និងកម្មវិធីថ្មីៗក្នុងតំបន់ ក៏ដូចជាក្រៅតំបន់ ដែលពាក់ព័ន្ធនិងបញ្ហាប្រជាជន និងការអភិវឌ្ឍ
- បំពេញភារកិច្ចផ្សេងៗ ទៀតតាមការប្រគល់ជូនរបស់អគ្គលេខាធិការនៃ **គ.ជ.ប.អ**។

## ជំពូកទី៥

## អវសានប្បញ្ញត្តិ

**មាត្រា ១៦.-**

រាល់បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា ១៧.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ **គ.ជ.ប.អ** និងអគ្គលេខាធិការដ្ឋានរបស់ **គ.ជ.ប.អ** មានភារកិច្ចអនុវត្តអនុក្រឹត្យនេះ ទៅតាមភារកិច្ចរៀងៗ ខ្លួនចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែ ឧសភា ឆ្នាំ ២០០៥

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**ចម្លងជូន:**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច និងឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ១៧
- ឯកសារ កាលប្បវត្តិ